ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន

*ប្រញាប់ណាស់*

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសជប៉ុន សូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋាភិបាលជប៉ុនបានដាក់ប្រទេសកម្ពុជាក្នុងបញ្ជីប្រទេសដែលមានជំងឺកូវីដ-១៩ទម្រង់ថ្មី បន្ទាប់ពីកម្ពុជាបានរកឃើញការឆ្លងជំងឺប្រភេទថ្មីនេះចំនួន ៣ករណីលើអ្នកដំណើរបរទេស ។ ការប្រកាសបញ្ចូលកម្ពុជាទៅក្នុងបញ្ជីនេះនឹងចូលជាធរមាននៅម៉ោង 00:00 ថ្ងៃទី០១ មីនា ២០២១ ។ រហូតមកដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ រដ្ឋាភិបាលជប៉ុនបានដាក់ប្រទេស/តំបន់ចំនួន៨៨ នៅក្នុងបញ្ជីប្រទេសជំងឺកូវីដ-១៩ទម្រង់ថ្មី ។

អ្នកដំណើរមកពីប្រទេស/តំបន់ទាំង៨៨នេះ តម្រូវឱ្យបង្ហាញមន្ត្រីអន្តោប្រវេសន៍ជប៉ុននូវលិខិតបញ្ជាក់សុខភាពអវិជ្ជមានកូវីដ១៩ ដែលធ្វើតេស្តក្នុងរង្វង់៧២ម៉ោងមុនធ្វើដំណើរ ហើយត្រូវធ្វើតេស្តកូវីដ-១៩ នៅពេលមកដល់ជប៉ុន ។ ក្នុងករណីមិនអាចផ្តល់លិខិតបញ្ជាក់សុខភាពអវិជ្ជមានកូវីដ-១៩ ជននោះនឹង ត្រូវស្នើឱ្យស្នាក់នៅរយៈពេល១៤ថ្ងៃ នៅទីតាំងណាមួយដែលកំណត់ដោយប្រធានស្ថានីយ៍ចត្តាឡីស័ក ។

ក្នុងករណីបងប្អូនចង់ប្រឹក្សាយោបល់ សូមទាក់ទង៖ **ហ្វេសប៊ុកស្ថានទូត** Royal Embassy of Cambodia in Japan ឬ **០៨០ ៤៦៨៩ ៩៣៧៤** ។

ថ្ងៃសៅរ៍ ១រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤
តូក្យូ ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២១

8-6-9 AKASAKA, MINATO-KU, TOKYO 107-0052
Tel : +81 3-5412-8521 Fax: +81 3-5412-8526
Email: camemb.jpn@mfaic.gov.kh